ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១១/២២ - ជីន ប៊ី ផាលេស ឯក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯក**
អាសយដ្ឋាន ៖ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ ៖ ០៩៧ ២៩០ ៧២ ៧៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក Martin | នាយកផ្នែកធនធានមនុស្ស និងរដ្ឋបាល |
| ២- លោក សេង អ៊ី | អនុប្រធានផ្នែករដ្ឋបាល |
| ៣- លោក ងុយ លីងួន | ប្រធានផ្នែកធនធានមនុស្ស |
| ៤- លោក ឡុង ឧត្តម | ប្រធានផ្នែកច្បាប់ |

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក លាស់ គឹមយោង | មេធាវី |
| ២- លោក ឡុង ឧត្តម | ប្រធានផ្នែកច្បាប់ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯក**
អាសយដ្ឋាន ៖ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ ៖ ០៩៦ ៤៨ ៣៤ ២៧២ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក ព្រិត សុអួត | មន្ត្រីជាន់ខ្ពស់ផ្នែកមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) |
| ២- លោក ជួង រ៉ាសនា | មន្ត្រីច្បាប់សហភាពការងារកម្ពុជា (CLC) |
| ៣- លោក ម៉ម រិទ្ធី | ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ សេវាកម្មកម្ពុជា (CTSWF) |
| ៤- លោក សារឹម សុភក្តិ | ប្រធានសហជីព (មូលដ្ឋាន) |
| ៥- លោក កាយ សារុជ | អនុប្រធានសហជីព (មូលដ្ឋាន) |
| ៦- លោកស្រី មុំ លក្ខិណា | លេខាសហជីព (មូលដ្ឋាន) |

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក ជួង រ៉ាសនា | មន្ត្រីច្បាប់សហភាពការងារកម្ពុជា (CLC) |
| ៧- លោក ម៉ម រិទ្ធី | ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ សេវាកម្មកម្ពុជា (CTSWF) |
| ២- លោក សារឹម សុភក្តិ | ប្រធានសហជីព (មូលដ្ឋាន) |
| ៣- លោក កាយ សារុជ | អនុប្រធានសហជីព (មូលដ្ឋាន) |
| ៤- លោកស្រី មុំ លក្ខិណា | លេខាសហជីព (មូលដ្ឋាន) |
| ៥- កញ្ញា ឈន ស្មើ | សមាជិកសហជីព |
| ៦- លោក ញ៉ វ៉ាន់ដា | សមាជិកសហជីព |
| ៧- កញ្ញា ជា ចាន់ណា | សមាជិកសហជីព |
| ៨- កញ្ញា ពែត ស្រីខ្មៅ | សមាជិកសហជីព |
| ៩- លោក គង់ សុខជា | សមាជិកសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- (ចំណុចទី១) ក្រុមហ៊ុនអនុវត្តវេនការងាររយៈពេល ១២ម៉ោង ក្នុងនោះ ៨ម៉ោង ធ្វើការធម្មតា ២ម៉ោងបន្ថែម រីឯ ២ម៉ោងទៀត ជាម៉ោងសម្រាក ដោយធ្វើការ ៤ថ្ងៃក្នុង ១សប្តាហ៍ ផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។ ចំណែកឯភាគីតំណាងកម្មករនិយោជិត ស្នើសុំឱ្យក្រុមហ៊ុនអនុវត្តម៉ោងការងាររយៈពេល ៨ម៉ោងក្នុងមួយថ្ងៃ។

២- (ចំណុចទី៣) ក្រុមហ៊ុននឹងរៀបចំទារកដ្ឋានប្រចាំសហគ្រាស ឬផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីដែលយកកូនផ្ញើទារកដ្ឋានខាងក្រៅតាមច្បាប់ (តំណាងកម្មករនិយោជិត (សហជីព) ស្នើឱ្យក្រុមហ៊ុនគំណត់ដាក់លាក់នូវប្រាក់ឧបត្ថម្ភសម្រាប់ជួលទារកដ្ឋាននៅខាងក្រៅ)។

៣- (ចំណុចទី៦) ក្រុមហ៊ុនមិនទាន់មានការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ព្រោះកំពុងផ្ទុះការរីករាលដាលនៃជំងឺកូវីដ-១៩ (អូមីក្រុង)។

៤- (ចំណុចទី៧) ការរាប់លុយធីប ក្រុមហ៊ុនមិនអាចអនុញ្ញាតឱ្យតំណាងកម្មករនិយោជិតចូលរាប់ជាមួយបានទេ (អនុញ្ញាតឱ្យតែ Shift Manager) ចំណែកឯប្រាក់ធីបកន្លងមក ក្រុមហ៊ុនបានបញ្ជាក់ថា បានទូទាត់រួចរាល់ហើយ។

៥- (ចំណុចទី៨) ក្រុមហ៊ុននឹងដំឡើងប្រាក់ឈ្នួលជូនកម្មករនិយោជិតតាមកិច្ចសន្យាការងារ ដោយផ្អែកលើការវាយតម្លៃសម្ថភាពការងារ និងស្ថានភាពសេដ្ឋកិច្ចក្រុមហ៊ុនជាក់ស្តែង។ ចំណែកឯកម្មករនិយោជិតសុំឱ្យអនុវត្តនូវអ្វីដូចមានចែងក្នុងកិច្ចសន្យាការងារ។

៦- (ចំណុចទី៩) ស្នើឱ្យក្រុមហ៊ុនទូទាត់ប្រាក់ដែលបុគ្គលិកធ្វើការចំថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាកផ្សេងៗ ទៅតាមច្បាប់ស្តីពីការងារ។

៧- (ចំណុចទី១០) ក្រុមហ៊ុននឹងផ្តល់ភាពងាយស្រួលជូនកម្មករនិយោជិត ក្នុងការឈប់សម្រាកផ្សេងៗ ផ្អែកលើមូលហេតុជាក់ស្តែង និងគោលការណ៍ឯកភាពក្រុមហ៊ុន។

៨- (ចំណុចទី១២) ក្រុមហ៊ុននឹងពិនិត្យលទ្ធភាពជួបប្រជុំពិភាក្សាជាមួយសហជីពមូលដ្ឋានស្របតាមស្ថានភាពជាក់ស្តែង។

៩- (ចំណុចទី១៣) ក្រុមហ៊ុននឹងអនុវត្តកិច្ចសន្យាការងារស្របតាមច្បាប់។

១០- (ចំណុចទី១៤) ក្រុមហ៊ុនអនុវត្តបទបញ្ញត្តិតាមច្បាប់ស្តីពីការងារ ក្នុងការបំពេញការងារ និងតាមគោលការណ៍ស្ម័គ្រចិត្ត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯក លេខ ១០២/២២ មកប/ខសន ចុះថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖

- លើកទី១ ៖ ថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២២ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។
- លើកទី២ ៖ ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០ នាទី រសៀល។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ បានទទួលពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ស្តីពីការទាមទាររបស់កម្មករនិយោជិត សុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ១៤ ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១០ ចំណុច លើការទាមទារចំនួន ១៤ ចំណុច។ ចំណុចមិនសះជាចំនួន ១០ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក លេខ ១០២/២២ មក ប/ខសន ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០២២។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា ចំនួន ២ លើក។ លើកទី១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក និងលើកទី២ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសការរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) និងបន្ទប់សវនាការត្រូវបានបែងចែករវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ នៅក្នុងសវនាការ ភាគីទាំងពីរមិនមានការជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការលើកទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់យកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ ឬភស្តុតាង និងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ឬភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ របស់ឈ្មោះ អ៊ឹង ដាក់ ជានាយកក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក Wartin William Jr Sim Song Yeow, លោក ងុយ លីងួន និងលោក ឡុង ឧត្តម ជាតំណាងក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២។

២- លិខិតផ្ទេរសិទ្ធិ របស់ឈ្មោះ អ៊ឹង ដាក់ ជានាយកក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក Wartin William Jr Sim Song Yeow, លោក ងុយ លីងួន , លោក លាស់ គីមឃាង និងលោក ឡុង ឧត្តម ជាតំណាងក្រុមហ៊ុន ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២។

៣- សារណាការពារសំណុំរឿងលេខ ០១១/២២ ចំណុចវិវាទ១០ ចំណុច ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

៤- លក្ខន្តិកៈក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក បានប្រថាបត្រាដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធឬលេខសម្គាល់៖ TRI2019010040027 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុម ជីន ប៊ី ផាលេស ឯ.ក លេខ MOC-៦២៥៧៨៤០២ ពណ.ចបព ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។

៦- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន លេខ ០៣/២០២២ ប.ស.ស.-បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២។

៧- ប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០២២ អ្នកជាប់ពន្ធធំ របស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ PTL ២០២២០២៣៤៦៧ អពដ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២។

៨- ឯកសាររបាយការណ៍ស្ថិតិកិច្ចសន្យាការងារថ្មី។

៩- ឯកសាររបាយការណ៍បុគ្គលិកបានយល់ព្រមកិច្ចសន្យាការងារ។

១០- ឯកសារកិច្ចព្រមព្រៀងការងារថ្មី។

១១- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក លេខ VATM ២០១៧១០៣៤៩ អពដ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨។

១២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក លេខ ០០៥/២០ មកប/ខសន ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។

១៣- លិខិតលេខ ០០៥/២០ មកប/ខសន ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករនិយោជិតក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

១៤- លិខិតលេខ ២៩៨/២២ អ.គ.ល.ក.ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ជម្រាបជូន លោក អ៊ឹង ដារ៉ា កម្មសិទ្ធិករ/អ្នកដាក់ពាក្យស្នើសុំ ស្តីពីការប្រជុំពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូរបស់ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក និងក្រុមហ៊ុន ខេមបូឌាន ហោង ស៊ីន រៀល អ៊ីស្ទេត ឯ.ក។

១៥- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដាររបស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ២០១៨។

១៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

១៧- សារណាការពារលើកទី២ របស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ស្តីពីភស្តុតាងបញ្ជាក់ពីភាពខុសគ្នារវាងក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក និងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។

១៨- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ DE20211774 អធក របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១។

១៩- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពទេសចរណ៍កម្ពុជាក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ ៣៦៧/២១ កប/វបវក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១។

២០- លក្ខន្តិកៈក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក បានប្រថាបត្រាដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ ឬលេខសម្គាល់៖ ១០២១៥២៩៩៣៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ នៅនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២១- អាជ្ញាបណ្ណទេសចរណ៍របស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ ០០៣ ក.ទ.ច នៃក្រសួងទេសចរណ៍ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២។

២២- លិខិតបញ្ជាក់របស់ក្រសួងទេសចរណ៍លេខ ០១៣ លអញបេ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២។

២៣- លិខិតលេខ ០១៣ សជណបេ របស់ក្រសួងទេសចរណ៍ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ជម្រាបមក លោក អ៊ឹង ដារ៉ា ម្ចាស់ភោជនីដ្ឋាន ជីន ប៊ី ផាលេស ឯ.ក ស្តីពីការស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ប្រកបអាជីវកម្មភោជនីដ្ឋាន។

២៤- អាជ្ញាបណ្ណទេសចរណ៍របស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ ០៤៧ ក.ទ.ច នៃក្រសួងទេសចរណ៍ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២។

២៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុម ជីន ប៊ី គ្រុប ឯ.ក លេខ MOC-៩៣១១៩៤៣ ពណ.ចបព ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។

THE ARBITRATION COUNCIL

២៦- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.កលេខ PTL-២០២១០៣៣៦៨៩ អពដ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១។

២៧- អាជ្ញាបណ្ណកាស៊ីណូ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក លេខ ២៣៦ សហវ.អឧហ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១។

២៨- ពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ របស់ប្រធានផ្នែកនីតិកម្ម គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីប្តឹងជំទាស់ឯកសាររបស់ ភាគីសហជីព ឬ កម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២៩- លិខិតបញ្ជាក់របស់កម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។

៣០- ឯកសារជាភាសាបរទេស។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ០៣៨ ២២/ស.ក.ក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ របស់ភាពការងារកម្ពុជា គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសុំចាត់តាំងមន្ត្រីសហភាពចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមកម្មករនិយោជិត និងនិយោជកនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។

២- លិខិតសុំជំនួយផ្នែកច្បាប់ និងប្រគល់សិទ្ធិ របស់តំណាងកម្មករនិយោជិត និងសមាជិកសហជីព នៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក គោរពចូលមក លោកប្រធានសហភាពការងារកម្ពុជា ស្តីពីការស្នើសុំជំនួយផ្លូវច្បាប់ និងប្រគល់សិទ្ធិជូន ដើម្បីដោះស្រាយវិវាទការងាររវាងយើងខ្ញុំ និងនិយោជកនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីន ប៊ី កួយ ជូ ) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២។

៣- លិខិតចាត់តាំងលេខ ០១៧ ២២/ACILS ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់មជ្ឈមណ្ឌលអាមេរិចកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ ហៅកាត់ ACILS គោរពជូន លោកប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការចាត់តាំងឈ្មោះ ព្រិត សុអួត មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ ចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមលេខ ០១១/២២ នៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។

៤- លិខិតចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ស្នើសុំជំនួយផ្លូវច្បាប់ និងប្រគល់សិទ្ធិចូលរួមដោះស្រាយវិវាទការងាររួម របស់សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ សេវាកម្មកម្ពុជា (CTSWF) គោរពជូន លោកនាយក មជ្ឈមណ្ឌលអាមេរិចកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS) ស្តីពីការស្នើសុំជំនួយផ្លូវច្បាប់ និងប្រគល់សិទ្ធិជូនដើម្បីដោះស្រាយវិវាទការងាររួមជាមួយក្រុមហ៊ុនកាស៊ីណូ ជីន ប៊ី គ្រុប ឯ.ក (ជីន ប៊ី កួយ ជូ) និងនិយោជកនៃក្រុមហ៊ុនកាស៊ីណូ ជីន ប៊ី គ្រុប ឯ.ក (ជីន ប៊ី កួយ ជូ)។

៥- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ របស់សហជីពកម្មករនិយោជិត នៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក លេខ ០០៥/២០ មកប/ខសន ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។

៦- លិខិតលេខ ០០៥/២០ មកប/ខសន ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករនិយោជិតក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៧- សារណារបស់តំណាងកម្មករនិយោជិត និងជាថ្នាក់ដឹកនាំសហជីព កម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីន ប៊ុ កួយ ជូ) គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំជូនសារណាការពាររបស់សហជីពតំណាងកម្មករ នៃក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីន ប៊ុ កួយ ជូ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

៩- លិខិតបញ្ជាក់ការព្រមព្រៀង ជូន លោក សារឹម សុភក្តិ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១។

១០- លិខិតអញ្ជើញលេខ ០១៣/២២ មកប/ខសន ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២។

១១- លិខិតលេខ ០១៥/២២ មកប/ខសន ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ ជម្រាបមក លោកនាយកក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក ស្តីពី ការពន្យាពេលចូលបំភ្លឺ និងផ្សះផ្សាវិវាទការងាររបស់ក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក។

១២- លិខិតលេខ ០០១/២២ មកប/ខសន/លបវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពី លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួ។

១៣- ប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ស្តីពី ការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា។

១៤- ប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពី ភាពជាតំណាងបំផុតនៃសហជីព និងបែបបទនិងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត។

១៥- ប្រកាសលេខ ០១៧ សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពី នីតិវិធីនៃការដោះស្រាយវិវាទការងាររួម។

១៦- កំណត់ហេតុរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីន ប៊ុ កួយ ជូ) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

១៧- ប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯក លេខ ១០២/២២ មកប/ខសន ចុះថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែមីនា ឆ្នាំ២០២២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

THE ARBITRATION COUNCIL

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯក លេខ ០០១/២២ មកប/ខសន/ល.ប.វ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៦៥ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៦៦ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ០៩២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ០៩៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកកាស៊ីណូ និងមានជួលកម្មករនិយោជិតសរុបចំនួន ៥៣៤នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក លេខ ១០២/២២ មកប/ខសន ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២២)*។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/២២ មកប/ខសន/ល.ប.វ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ដែលមានកម្មករនិយោជិតចំនួន ២នាក់ រួមមាន ៖ ១. លោក សារីម សុភក្តិ និង២. លោក កាយ សាវុធ។
- ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក និងក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក គឺជាក្រុមហ៊ុនពីរផ្សេងគ្នា។ ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ ក.បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០៤៦០៦៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។ ដោយឡែក ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០២៣៩៥៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។
- នៅថ្ងៃសវនាការ ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក មានសកម្មភាពចម្បងផ្នែកសណ្ឋាគារ ភោជនីយដ្ឋាន និងកាស៊ីណូ ចំណែកឯ ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក មានសកម្មភាពចម្បងផ្នែក កាស៊ីណូតែប៉ុណ្ណោះ។

THE ARBITRATION COUNCIL

សវនាការលើកទី១ ៖

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងពីឈ្មោះក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០២៣៩៥៦ មានឈ្មោះ ក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក ដោយមិនមានបញ្ជាក់ពាក្យ "ជីនប៊ុ កួយជូ" នៅខាងក្រោយឈ្មោះក្រុមហ៊ុននោះទេ។ ភាគីនិយោជក និងភាគីកម្មករនិយោជិត មិនបានជំទាស់ថា ឈ្មោះក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក និងក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ជាឈ្មោះរបស់ក្រុមហ៊ុនពីរផ្សេងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា ឈ្មោះក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក នៅក្នុងបញ្ជីពាណិជ្ជកម្មខាងលើ និងក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ដែលកម្មករនិយោជិតលើកឡើងនៅក្នុងសវនាការ គឺជាឈ្មោះក្រុមហ៊ុនតែមួយ។

- នៅពេលចាប់ផ្តើមសវនាការ ភាគីនិយោជកបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចប់សំណុំរឿងនេះ ដោយមូលហេតុដូចខាងក្រោម ៖
    - កម្មករនិយោជិតបានប្តឹងខុសក្រុមហ៊ុន ពីព្រោះកម្មករនិយោជិតដែលទាមទារ គឺជាកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ប៉ុន្តែពួកគាត់បែរជាទាមទារមកនិយោជកនៃក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ ក.ទៅវិញ។
    - នៅក្នុងក្រុមហ៊ុន ហ៊ុន ជីន ប៊ុ ផាលេស ឯ.ក មិនមានវិវាទកើតឡើងរវាងកម្មករនិយោជិត និងនិយោជកនោះទេ។
    - និយោជកបានបញ្ជាក់ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ រួចហើយថាក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក គឺជាក្រុមហ៊ុនផ្សេងពីក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ)។
    - ថ្វីបើក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក និងក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ស្ថិតនៅក្នុងទីតាំងតែមួយ ប៉ុន្តែក្រុមហ៊ុនទាំងពីរមិនមែនជាក្រុមហ៊ុនតែមួយនោះទេ ពីព្រោះថាក្រុមហ៊ុនទាំងពីរមានអាជ្ញាប័ណ្ណ លក្ខន្តិកៈ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន និងកម្មករនិយោជិតផ្សេងគ្នាទាំងអស់។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ៖
    - ពេលមានការផ្សះផ្សានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ និយោជកមិនមានការជំទាស់ថា កម្មករនិយោជិតបានប្តឹងខុសក្រុមហ៊ុននោះទេ។ ម្យ៉ាងទៀត និយោជក៏បានចូលរួមផ្សះផ្សា និងចុះកិច្ចព្រមព្រៀងជាមួយកម្មករនិយោជិតផងដែរ។
    - កម្មករនិយោជិតដែលផ្តិតមេដៃទាមទារ គឺមានកម្មករនិយោជិតខ្លះស្ថិតនៅក្នុងក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក ដោយហេតុថា កម្មករនិយោជិតមិនបានដឹងថា និយោជិតបានផ្លាស់ប្តូរកិច្ចសន្យាការងាររបស់កម្មករនិយោជិតពីក្រុមហ៊ុន ជីន ប៊ុ គ្រុប ឯ.ក (ជីនប៊ុ កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក។ ក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនទាន់អាចកំណត់បានទេថា មានកម្មករនិយោជិតចំនួនប៉ុន្មាននាក់ដែលកំពុងធ្វើការនៅក្រុមហ៊ុន ជីន ប៊ុ ផាលេស ឯ.ក បានផ្តិតមេដៃទាមទារនៅក្នុងសំណុំរឿងនេះទេ។

THE ARBITRATION COUNCIL

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ការទាមទារនៅក្នុងសំណុំរឿងនេះធ្វើឡើងសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្នុងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក និងក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ)។
- នៅថ្ងៃសវនាការលើកទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាឱ្យភាគីកម្មករនិយោជិតដាក់បញ្ជីឈ្មោះកម្មករនិយោជិតដែលកំពុងធ្វើការនៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ដោយស្រង់ចេញពីឈ្មោះកម្មករនិយោជិតដែលបានផ្តិតមេដៃទាមទារ។ ភាគីនិយោជកមានកាតព្វកិច្ចពិនិត្យបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារ និងបញ្ជាក់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រសិនបើមិនមានឈ្មោះកម្មករនិយោជិតដែលកំពុងធ្វើការនៅក្នុងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។
- ភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវឯកសារ កស្តុតាង ដូចខាងក្រោម ៖
    - កំណត់ហេតុ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ដែលមានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតចំនួន ៥៧នាក់ ដោយកំណត់ថា ៖ "*យើងខ្ញុំទាំងអស់គ្នា ជាកម្មករនិយោជិត នៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី កួយ ជូ)...*

      *សូមបញ្ជាក់ថា...យើងខ្ញុំទាំងអស់គ្នា សូមបដិសេធនូវកិច្ចព្រមព្រៀងការងារ ឬកិច្ចសន្យាការងារដែលយើងខ្ញុំទាំងអស់គ្នាបានចុះហត្ថលេខជាមួយក្រុមហ៊ុននាពេលកន្លងមក ដោយសារយើងខ្ញុំទាំងអស់គ្នាមិនបានយល់ដឹងអំពីអត្ថន័យនិងខ្លឹមសារនៃកិច្ចព្រមព្រៀងការងារ ឬកិច្ចសន្យាការងារឱ្យបានស៊ីជម្រៅ ថែមទាំងមិនបានយល់អំពីផ្លូវច្បាប់។ បន្ថែមជាងនេះទៀត កិច្ចព្រមព្រៀង ឬកិច្ចសន្យាការងារនេះ គឺធ្វើឡើងជាភាសាអង់គ្លេស...ដែលធ្វើឱ្យយើងខ្ញុំទាំងអស់គ្នាមិនអាចយល់បាន។*

      *...ការចុះហត្ថលេខានេះ គឺធ្វើឡើងដោយការបង្ខិតបង្ខំ និងមានការភ័យខ្លាចបាត់បង់ការងារព្រមទាំងទទួលពាក្យគំរាមគំហែង ផ្សេងៗ...ពីថ្នាក់គ្រប់គ្រង។...*

      *...យើងខ្ញុំទាំងអស់គ្នា មិនបានដឹងថាក្រុមហ៊ុនបានផ្លាស់ប្តូរយើងខ្ញុំទាំងអស់គ្នាពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី កួយ ជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះឡើយ ហើយកិច្ចសន្យាចាស់យើងខ្ញុំទាំងអស់គ្នា ក៏មិនទាន់បានបញ្ចប់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី កួយ ជូ) ទេ ថែមទាំងមិនទទួលបានប្រាក់ទូទាត់នៃការបញ្ចប់កិច្ចសន្យាការងារជាមួយក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី កួយ ជូ) នៅឡើយ...*

      *ដើម្បីបញ្ជាក់ពីការពិតចំពោះមុខច្បាប់ យើងខ្ញុំទាំងអស់គ្នាសូមផ្តិតមេដៃទុកជាកស្តុតាង...*"។
    - សារណាបស់ភាគីកម្មករនិយោជិតចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ដែលមានខ្លឹមសារថា ៖ "*...ក្រុមហ៊ុន ជីន ប៊ីន ក្រុម ឯ.ក ត្រូវបានបង្កើតឡើងដើម្បីប្រតិបត្តិការអាជីវកម្មការស៊ីណូ...ត្រូវបានក្រុមហ៊ុនធ្វើទុកបុកម្ហេញដោយបង្ខំឱ្យកម្មករនិយោជិតដែលមានអតីតភាពការងារច្រើនក្នុងក្រុមហ៊ុននេះលាឈប់ពីការងារ ហើយត្រូវបានបង្ខំឱ្យចុះកិច្ចព្រមព្រៀងការងារ ឬកិច្ចសន្យាការងារសាកល្បងថ្មីជាមួយក្រុមហ៊ុនមួយទៀតឈ្មោះថា ជីន ប៊ីផាលេស ដែលមានថៅកែ និងអ្នកគ្រប់គ្រងផ្នែកធនធានមនុស្សតែមួយ។....*

      *លើសពីនេះទៀត កម្មករនិយោជិតមិនបានដឹងពីល្បិចកលរបស់ក្រុមហ៊ុន ដែលផ្លាស់ប្តូរពួកគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី កួយ ជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះឡើយ ហើយកិច្ចសន្យាចាស់របស់ពួកគាត់ ក៏មិនទាន់បានបញ្ចប់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប*

THE ARBITRATION COUNCIL

*ឯ.ក(ជីន ប៊ី គួយ ជូ) ទេ ថែមទាំងមិនទទួលបានប្រាក់ទូទាត់នៃការបញ្ចប់កិច្ចសន្យាការងារ ជាមួយក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក(ជីន ប៊ី គួយ ជូ) នៅឡើយ...(កំណត់ហេតុរបស់កម្មករនិយោជិត)។...។"*

- ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវឯកសារ ភស្តុតាង ដូចខាងក្រោម ៖
  - ពាក្យបណ្តឹងរបស់និយោជក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ដែលប្តឹងជំទាស់ឯកសាររបស់ភាគីសហជីព ឬកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ ដោយកំណត់ថា ៖ *"...ភាគីសហជីព ឬកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក បានញុះញង់បុគ្គលិកក្រុមហ៊ុនជីនប៊ីផាលេស ឯ.ក មិនឱ្យគោរពកិច្ចសន្យាការងារ ខុសពីស្មារតីនៃកិច្ចសន្យា មិនស្មោះត្រង់ និងសុចរិត ដែលបណ្តាលឱ្យប៉ះពាល់ការងាររបស់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក*
    *...ភាគីសហជីព ឬកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក បានញុះញង់ និងបំភ័ន្តការពិតទៅប្រាប់បុគ្គលិកក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ឱ្យយល់ខុស និងផ្តិតម្រាមដៃធ្វើការឆបោក...*
    *...ភាគីសហជីព ឬកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក បានប្រើប្រាស់ល្បិចកល បន្លំបុគ្គលិកក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ដើម្បីចង់បានស្នាមម្រាមដៃ ទាំងបុគ្គលិកខាងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ...មិនបានយល់ពីកម្មវត្ថុ ឬគោលបំណងរបស់ក្រុមសហជីព ឬកម្មករនិយោជិត នៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ឡើយ (មានភស្តុងតាមភ្ជាប់មកជាមួយ)...។"*
  - លិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដែលមានចំនួន ២០ ច្បាប់ និងធ្វើឡើងដោយកម្មករនិយោជិត ២០នាក់ ផ្សេងៗគ្នា។ ក្នុងនោះមានកម្មករនិយោជិតចំនួន ១៥នាក់ ដែលបានផ្តិតមេដៃក្នុងកំណត់ហេតុ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ របស់សហជីព ឬកម្មករនិយោជិតនៃក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក។ យ៉ាងណាមិញ នៅក្នុងលិខិតនោះ មិនមានឃ្លាណាមួយបញ្ជាក់ថា ភាគីកម្មករនិយោជិតឈប់ទាមទារនៅក្នុងសំណុំរឿងនោះទេ។

**សវនាការលើកទី២ ៖**

- ភាគីកម្មករនិយោជិតបានលើកឡើងថា ៖
  - នៅក្នុងបណ្តឹងដើមរបស់កម្មករនិយោជិតទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ គឺប្តឹងទាមទារក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី គួយជូ)។ ដោយឡែក កម្មករនិយោជិតមិនបានដឹងថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ និងនិយោជកបានផ្លាស់ប្តូរ ឈ្មោះក្រុមហ៊ុន មកជាក្រុមហ៊ុនជីន ប៊ី ផាលេស ឯ.ក នោះទេ។ ប្រសិនបើកម្មករនិយោជិតប្តឹងខុសក្រុមហ៊ុន ហេតុអ្វីបានជានិយោជកនៃក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ចូលរួមផ្សះផ្សា ព្រមទាំងមានចុះកិច្ចព្រមព្រៀងជាមួយកម្មករនិយោជិត។
  - កម្មករនិយោជិតដែលទាមទារ មានកម្មករនិយោជិតខ្លះ ជាកម្មករនិយោជិតដែលធ្វើការងារនៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ដោយពួកគាត់ជាអតីតកម្មករនិយោជិតដែលធ្វើការនៅក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី គួយជូ)។

THE ARBITRATION COUNCIL

- កម្មករនិយោជិតមិនបានដឹងថា និយោជកផ្លាស់ប្តូរពួកគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះទេ។
- នៅថ្ងៃសវនាការលើកទី២ មានកម្មករនិយោជិតចំនួន ៥នាក់ បានចូលរួមសវនាការអាជ្ញាកណ្តាល ដោយបញ្ជាក់ថា ពួកគាត់តំណាងឱ្យកម្មករនិយោជិតចំនួន ៥៤នាក់ ដែលមិនបានដឹងថា និយោជកផ្លាស់ប្តូរការងារពួកគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។
- និយោជកបានចុះកិច្ចសន្យាការងារថ្មីជាមួយនឹងកម្មករនិយោជិតដោយមានការបោកបញ្ឆោត។ កិច្ចសន្យាការងារថ្មីនេះធ្វើឡើងជា ២ភាសា គឺភាសាអង់គ្លេស និងភាសាខ្មែរ។ នៅក្នុងកិច្ចសន្យាការងារជាភាសាខ្មែរមានចំណុចខ្លះមិនបានបកប្រែពីភាសាអង់គ្លេសបានអស់អត្ថន័យនោះទេ។ កម្មករនិយោជិតសុំប្រានចោលកិច្ចសន្យាការងារដែលបានចុះជាមួយនិយោជក។
- ករណីនេះ កម្មករនិយោជិតឈ្មោះ ញ៉ វ៉ាន់ដា ផ្នែកបេឡា បានចុះហត្ថលេខាលើកិច្ចសន្យាការងារថ្មី នៅខែមករា ឆ្នាំ២០២២ ប៉ុន្តែគាត់មិនបានដឹងថា និយោជកផ្លាស់ប្តូរការងារគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះទេ។ និយោជកបានឱ្យគាត់ចុះហត្ថលេខាលើកិច្ចសន្យាការងារដែលធ្វើជាភាសាអង់គ្លេសតែប៉ុណ្ណោះ ប៉ុន្តែគាត់តែមិនបានចុះហត្ថលេខាលើកិច្ចសន្យាការងារជាភាសាខ្មែរនោះទេ។ ក្នុងកិច្ចសន្យាជាភាសាអង់គ្លេស គឺមាននិមិត្តសញ្ញា (Logo) ក្រុមហ៊ុន ហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ប៉ុន្តែ នៅផ្នែកខាងក្រោមកិច្ចសន្យាសសេរថា ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។
- ករណីកម្មករនិយោជិត ជា ចាន់ណា បានចុះហត្ថលេខាលើកិច្ចសន្យាការងារថ្មី នៅខែកុម្ភៈ ឆ្នាំ ២០២២។ នៅពេលចុះកិច្ចសន្យាការងារថ្មីនេះ ផ្នែករដ្ឋបាលបានបញ្ជាក់ថា គាត់ត្រូវបំពេញការងារចំនួន ១២ម៉ោង ក្នុងមួយថ្ងៃ ប៉ុន្តែ គាត់សុំធ្វើការតែចំនួន ៨ម៉ោង ប៉ុណ្ណោះ។ តែយ៉ាងណាមិញ ផ្នែករដ្ឋបាលបានលើកឡើងថា ប្រសិនបើគាត់មិនព្រមចុះហត្ថលេខានោះ និយោជកនឹងមានវិធានការផ្សេងទៀត។ ម្យ៉ាងទៀត គាត់មិនបានដឹងថា និយោជកបានផ្លាស់ប្តូរការងារគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះទេ ដោយផ្នែករដ្ឋបាលគ្រាន់តែបានអានកិច្ចសន្យាការងារជាភាសាខ្មែរឱ្យគាត់ស្តាប់ និងមិនបានប្រាប់គាត់ថា មានការផ្លាស់ប្តូរក្រុមហ៊ុននោះទេ។ ហេតុនេះ គាត់ស្នើសុំអនុវត្តកិច្ចសន្យាការងារចាស់របស់គាត់វិញ។

- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតនៅក្នុងសំណុំរឿងនេះបានប្តឹងទាមទារទៅកាន់ក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) តាំងពីដំបូង ហើយរហូតដល់ពេលនេះ នៅតែប្តឹងទាមទារចំពោះក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) ដដែល។
- ភាគីនិយោជកបានលើកឡើងថា ៖
  - កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក មានកិច្ចសន្យាការងារត្រឹមត្រូវជាមួយនិយោជក ហើយពួកគាត់មិនមានវិវាទជាមួយក្រុមហ៊ុននោះទេ។
  - នៅពេលចុះកិច្ចសន្យាការងារថ្មី និយោជកបានទុកពេលឱ្យកម្មករនិយោជិតពិនិត្យ ទោះបីជាកិច្ចសន្យាជាភាសាអង់គ្លេស ប៉ុន្តែនិយោជកបានបកប្រែជាភាសាខ្មែរជូនកម្មករនិយោជិតផងដែរ។

THE ARBITRATION COUNCIL

○ និយោជកបដិសេធកម្មករនិយោជិតចំនួន ៥៤នាក់ ដែលកម្មករនិយោជិតបានលើកឡើងថាធ្វើការនៅក្នុងក្រុមហ៊ុន ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក។
○ និយោជកទទួលស្គាល់ថា ក្នុងចំណោម កម្មករនិយោជិតដែលចូលរួមសវនាការលើកទី២ នេះមានកម្មករនិយោជិតចំនួន ៤នាក់ប៉ុណ្ណោះ ដែលធ្វើការនៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ករួមមាន ៖ ១. រ៉េត ស្រីឡែន, ២. ញ៉ វ៉ាន់ដា, ៣. គង់ សុខដា, និង ៤. អេន សារ៉ាយ។ ចំពោះកម្មករនិយោជិត ដា ចាន់ណា ត្រូវបាននិយោជកបញ្ឈប់ពីការងារហើយ។

## ហេតុផលនៃសេចក្ដីសម្រេច ៖

ផ្អែកតាមអង្គហេតុ ភាគីនិយោជកទទួលស្គាល់ថា មានកម្មករនិយោជិតចំនួន ៤នាក់ ដែលមានវត្តមាននៅក្នុងសវនាការជាកម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក ប៉ុន្តែកម្មករនិយោជិតរបស់ខ្លួន មិនមានវិវាទជាមួយក្រុមហ៊ុនទេ ហើយនិយោជកមិនអាចដោះស្រាយវិវាទក្នុងសំណុំរឿងនេះទេ ព្រោះនិយោជកមិនមែនជាភាគីនៃវិវាទនេះ។ យ៉ាងណាមិញ ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតមិនបានដឹងថានិយោជកផ្លាស់ប្ដូរកិច្ចសន្យាការងាររបស់ពួកគាត់ពីក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីន ប៊ី កួយជូ) ទៅក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះទេ។ នៅក្នុងបណ្ដឹងដើមរបស់ភាគីកម្មករនិយោជិតដែលដាក់ទៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ គឺកម្មករនិយោជិតប្ដឹងទាមទារក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីន ប៊ី កួយជូ)។ ករណីនេះ នៅក្នុងសវនាការលើកទី១ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការទាមទារនៅក្នុងសំណុំរឿងនេះធ្វើឡើងសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្នុងក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក និងក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ)។ ដោយឡែក នៅក្នុងសវនាការលើកទី២ ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថាកម្មករនិយោជិតប្ដឹងទាមទារទៅក្រុមហ៊ុន ជីន ប៊ី គ្រុប ឯ.ក (ជីនប៊ី កួយជូ) មិនមែនប្ដឹងទៅកាន់ក្រុមហ៊ុន ជីន ប៊ី ផាលេស ឯ.ក នោះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណា ដូចខាងក្រោម៖

កថាខណ្ឌទី១ មាត្រា ៣១២ នៃច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។"*

ប្រការ ៣៣ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចែងថា ៖ *"អំណាចរបស់ក្រុមអាជ្ញាកណ្ដាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ។"*

ប្រការ ៣៤ នៃប្រកាស ០៩៩ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែងថា ៖ *"ចំពោះបញ្ហាដែលបានដាក់ជូនក្រុមអាជ្ញាកណ្ដាល ក្រុមនេះមានសិទ្ធិ និង អំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្ដល់សំណងយ៉ាងពេញលេញចំពោះរាល់ការបំពានបទបញ្ញត្តិដែលមាននៅក្នុងច្បាប់ស្ដីពីការងារ..."*។

យោងតាមមាត្រា ៣១២ នៃច្បាប់ស្ដីពីការងារ, ប្រការ ៣៣ នៃប្រកាសលេខ ០៩៩ សកបយ. ខាងលើក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានអំណាចពិចារណាលើវិវាទមួយ ដោយពិនិត្យមើលលើបញ្ហាទាំងឡាយណាដែលស្ថិតនៅក្នុងកំណត់ហេតុមិនសះជាដែលបញ្ជូនមក

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែប៉ុណ្ណោះ។ ចំណែកឯបញ្ហាដែលមិនមាននៅក្នុងកំណត់ហេតុមិនសះជា ដែលភាគីលើកឡើងនៅក្នុងសវនាការ បញ្ជាក់ពីការទាមទារបន្ថែម ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការពិចារណាបានលុះត្រាតែចំណុចវិវាទនោះ គឺជាបញ្ហាកើតក្រោយការធ្វើកំណត់ហេតុ ដែលជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។ លើសពីនេះ ប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ. បានកំណត់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់សំណងចំពោះការបំពានច្បាប់។ ករណីនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទដែលកំណត់ក្នុងប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ. គឺសំដៅលើភាគីកម្មករនិយោជិត និងនិយោជក ដែលមានកំណត់នៅក្នុងកំណត់ហេតុមិនសះជាដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។

យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ១០២/២២ មកប/ខសន ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះសីហនុ ដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ជាកំណត់ហេតុមិនសះជារវាងកម្មករនិយោជិត និងនិយោជកនៃក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក។ ហេតុនេះ នៅក្នុងសំណុំរឿងដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ភាគីវិវាទ គឺរវាងកម្មករនិយោជិត និងក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក (ជាភាគីនិយោជក)។

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះបានទាមទារទៅកាន់និយោជកនៃក្រុមហ៊ុន ជីន ប៉ី គ្រុប ឯ.ក (ជីនប៉ី កួយជូ) មិនមែនទាមទារទៅកាន់និយោជកនៃក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក នោះទេ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថាក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក និងក្រុមហ៊ុន ជីន ប៉ី គ្រុប ឯ.ក គឺជាក្រុមហ៊ុនពីរផ្សេងគ្នា ដោយហេតុថា ក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០៤៦០៦៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ រីឯក្រុមហ៊ុន ជីន ប៉ី គ្រុប ឯ.ក បានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០២៣៩៥៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា កម្មករនិយោជិតមិនមានវិវាទជាមួយនឹងនិយោជកនៃក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក នៅក្នុងសំណុំរឿងនេះទេ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានរកឃើញដែរថា ការទាមទាររបស់កម្មករនិយោជិតទៅកាន់ក្រុមហ៊ុន ជីន ប៉ី គ្រុប ឯ.ក គឺជាការទាមទារទៅភាគីផ្សេងទៀត ដែលមិនមែនជាភាគីវិវាទនៅក្នុងកំណត់ហេតុមិនសះជាដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ យោងតាមការបកស្រាយនៃមាត្រា ៣១២ នៃច្បាប់ស្តីពីការងារ, ប្រការ ៣៣ និងប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ. ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការពិចារណា ដើម្បីដោះស្រាយវិវាទរវាងកម្មករនិយោជិត និងនិយោជកដែលមិនមែនជាភាគីនៃវិវាទនៅក្នុងកំណត់ហេតុមិនសះជានឹងគ្នានោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាសំណុំរឿងលេខ ០១១/២២-ក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក នេះ។

## សម្រេច និងបង្គាប់

- បដិសេធពិចារណាសំណុំរឿងលេខ ០១១/២២-ក្រុមហ៊ុន ជីន ប៉ី ផាលេស ឯ.ក។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា ៖-----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------------